# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ : ០៧០ គ.ជ.ប. ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការកំណត់បែងចែកអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមមណ្ឌលភូមិភាគ ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី ៤ ថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨

### គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់

- បានឃើញសេចក្តីសម្រេចលេខ ៩៨ ស.ស.រ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលកាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សម្រាប់នីតិកាលទី៤ នៃព្រឹទ្ធសភា
- បានឃើញសេចក្តីសម្រេចលេខ ០៩៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ៧២០ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨
- យោងប្រតិទិននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ឆ្នាំ២០១៨(វិសោធនកម្ម)
- យោងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០៧៩ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៨ ស្តីពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

## សម្រេច

**ប្រការ ១ .-**

កំណត់បែងចែកអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលភូមិភាគទាំង ៨ ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ដូចខាងក្រោម ៖

- **មណ្ឌលភូមិភាគទី ១ : ក្នុងចំនួនអាសនៈរួម ៦ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៦ អាសនៈ**
- **មណ្ឌលភូមិភាគទី ២ : ក្នុងចំនួនអាសនៈរួម ៨ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៨ អាសនៈ**
- **មណ្ឌលភូមិភាគទី ៣ : ក្នុងចំនួនអាសនៈរួម ៥ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៥ អាសនៈ**
- **មណ្ឌលភូមិភាគទី ៤ : ក្នុងចំនួនអាសនៈរួម ១០ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ១០ អាសនៈ**
- **មណ្ឌលភូមិភាគទី ៥ : ក្នុងចំនួនអាសនៈរួម ៧ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៧ អាសនៈ**

- មណ្ឌលភូមិភាគទី ៦ : ក្នុងចំនួនអាសនៈរួម ៧ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៧ អាសនៈ
- មណ្ឌលភូមិភាគទី ៧ : ក្នុងចំនួនអាសនៈរួម ៩ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៩ អាសនៈ
- មណ្ឌលភូមិភាគទី ៨ : ក្នុងចំនួនអាសនៈរួម ៦ ត្រូវបានទៅគណបក្សប្រជាជនកម្ពុជា ៦ អាសនៈ

**ប្រការ ២.-**

សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ ៣ .-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ជាសាធារណៈឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ។

ថ្ងៃសៅរ៍ ២ រោច ខែជេស្ឋ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៨

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក

**<u>ចម្លងជូន</u>**

- ខុទ្ទកាល័យព្រះមហាក្សត្រ
«ដើម្បីទូលថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប»
- ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- រាជរដ្ឋាភិបាល
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
«ដើម្បីជូនជ្រាប »
- ដូចប្រការ៣ « ដើម្បីអនុវត្ត »
- បណ្ណសារដ្ឋានជាតិ
- ឯកសារ-កាលប្បវត្តិ